# តារាងស្ដីពីព័ត៌មានរបស់គម្រោង

លេខPIP : 463

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : មជ្ឈមណ្ឌលសន្និសីទនិងពិព័រណ៍កម្ពុជា

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្ដើមគម្រោង 01/01/26

កាលបរិច្ឆេទបញ្ចប់គម្រោង 31/12/28

៣. ចំណាយគម្រោងសរុប $188,687,500

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងពាណិជ្ជកម្ម

RESPONSIBLE UNIT

អង្គភាពទទួលខុសត្រូវ អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម

៥. ស្ថានភាពគម្រោង គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ថវិកាជាតិ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី២- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

កម្ពុជា នឹងមានភារៈកិច្ចក្នុងការរៀបចំមជ្ឈមណ្ឌលសន្និសីទ និងពិព័រណ៍កម្ពុជា ស្របតាមការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួន។ គម្រោងដែលមានការប្ដេជ្ញចិត្តដ៏ខ្លាំងក្លាឆ្ពោះទៅរកឧស្សាហូបនីយកម្មការរៀបចំសម្រាប់នាំចេញ ដែលឧស្សាហកម្មរៀបចំសម្រាប់នាំចេញនឹងជាចលករសម្រាប់កំណើនសេដ្ឋកិច្ច។ ដើម្បីសម្រេចតាមគោលដៅនេះ មជ្ឈមណ្ឌលពិព័រណ៍ពាណិជ្ជកម្មកម្ពុជា នឹងដើរតួនាទីសំខាន់សម្រាប់ជំរុញការនាំចេញផលិតផលរបស់កម្ពុជា ។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? គាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម Industry and Support Services

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

គ្រប់ខេត្តក្រុង,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គោលបំណងនៃការបង្កើតមជ្ឈមណ្ឌលសន្និសីទ និងពិព័រណ៍កម្ពុជា ដើម្បីលើកកម្ពស់ និងជំរុញផលិតផលកម្ពុជា សម្រាប់ការប្រើប្រាស់នៅលើទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ ។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

+ ការងារប្រតិបត្តិ៖

- បង្កើតក្រុមការងារដែលមានក្រសួងពាណិជ្ជកម្មជាប្រធាន និងមានការចូលរួមដូចជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត
- សិក្សា ពិគ្រោះយោបល់ លើលទ្ធភាពបង្កើតមជ្ឈមណ្ឌល ការកំណត់ទីតាំង និងប្លង់សាងសង់
- ចុះសិក្សាស្វែងយល់ និងដកបទពិសោធន៍ពីការបង្កើត ការគ្រប់គ្រងមជ្ឈមណ្ឌល នៅប្រទេសគំរូមួយចំនួន តាមការចាំបាច់
- រៀបចំសរសេរគម្រោង និងផែនការសកម្មភាពជាមួយដៃគូអភិវឌ្ឍន៍
- អនុវត្តគម្រោង និងផែនកាសកម្មភាពសាងសង់
- ចុះត្រួតពិនិត្យ និងតាមដានជាប្រចាំលើគ្រប់ដំណាលកាលនៃដំណើរការសាងសង់
- វាយតម្លៃបញ្ចប់ការសាងសង់
- ជ្រើសរើសដៃគូអភិវឌ្ឍន៍ ឬក្រុមហ៊ុនដៃគូជាមួយក្រសួងក្នុងការគ្រប់គ្រង

+ មជ្ឈមណ្ឌល មានទំហំប៉ាន់ស្មានសរុប ៥០,០០០ ម២ នឹងបំពាក់នូវសម្ភារៈ និងគ្រឿងសង្ហារិម។

តម្លៃប៉ាន់ស្មាននៃការវិនិយោគមានទឹកប្រាក់ចំនួន ១៨៨,៦៨៧,៥០០ ដុល្លារសហរដ្ឋអាម៉េរិក ក្នុងនោះការចំណាយរួមមាន៖

- ដី ៤៨,៥០០,០០០ ដុល្លារសហរដ្ឋអាម៉េរិក
- សំណង់អគារមជ្ឈមណ្ឌល ៨៦,២៥០,០០០ ដុល្លារសហរដ្ឋអាម៉េរិក
- សម្ភារៈបរិក្ខារ ១៤,៣៧៥,០០០ ដុល្លារសហរដ្ឋអាម៉េរិក
- ការសិក្សាអំពីលទ្ធភាព ៤,០៨២,៥០០ ដុល្លារសហរដ្ឋអាម៉េរិក
- ការពិគ្រោះ និងរចនាបទ ៣,២២០,០០០ ដុល្លារសហរដ្ឋអាម៉េរិក
- ការងារប្រតិបត្តិ ២៨,៨១០,០០០ ដុល្លារសហរដ្ឋអាម៉េរិក
- បង្ការហានិភ័យ ១០% ៣,៤៥០,០០០ ដុល្លារសហរដ្ឋអាម៉េរិក

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

កម្ពុជា គឺជាសមាជិកអាស៊ាន អង្គការពាណិជ្ជកម្មពិភពលោក និងបានសមាហរណកម្មខ្លួនទៅក្នុងតំបន់ ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) ដែលកម្ពុជានឹងជួបប្រឈមជាមួយនឹងបណ្តាញប្រកួតប្រជែងអន្តរជាតិនៅក្នុងទីផ្សារនាំចេញនៃ AFTA ហើយកម្ពុជានឹងត្រូវការយន្តការជំរុញការនាំចេញដែលមានប្រសិទ្ធភាពថែមទៀត។ ក្នុងស្ថានភាពនាពេលបច្ចុប្បន្ននេះ ស្ទើតែប្រទេសនៃអាស៊ានទាំងអស់មាននូវយន្តការជំរុញពាណិជ្ជកម្មប្រភេទនេះ ដែលមានន័យថាកម្ពុជានឹងស្ថិតនៅខាងក្រោយប្រទេសអាស៊ានដទៃទៀតបើសិនជាគ្មានមជ្ឈមណ្ឌលនេះទេ។ បើសិនជាមជ្ឈមណ្ឌលនេះដំណើរការល្អ ជាបង្គោលសម្រាប់ពាណិជ្ជកម្ម និងវិនិយោគ មជ្ឈមណ្ឌលនឹងពង្រីកការជំរុញការនាំចេញផលិតផលកម្ពុជា ក៏ដូចជាជំនួសការនាំចូលដោយប្រើប្រាស់ផលិតផលរបស់កម្ពុជា ដែលនឹងធ្វើឱ្យសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

ក្រុមហ៊ុនឯកជននៅក្នុងស្រុកដែលត្រៀមខ្លួនសម្រាប់នាំចេញ ក៏ដូចជាអ្នកនាំចូលក្នុងស្រុក។ ការប៉ាន់ស្មាន ៤,០០០ ក្រុមហ៊ុនឯកជនសក្តានុពល មានប្រមាណ ៥០ក្រុមហ៊ុន នឹងប្រើប្រាស់សម្ភារៈបរិក្ខារបស់មជ្ឈមណ្ឌល។ ជាងនេះទៅទៀតក្រុមហ៊ុនឯកជនដែលរៀបចំសម្រាប់នាំចេញ និងក្រុមហ៊ុនពាណិជ្ជកម្មក្នុងរាជធានីភ្នំពេញ ក្រុមអ្នកផលិតផលិតផលក្នុងស្រុក នឹងទទួលប្រយោជន៍ពីមជ្ឈមណ្ឌលនេះ។

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | **មាន** |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | **ត្រូវបានរៀបចំ** |

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះ នឹងមិនមានផលប៉ះពាល់ដល់បរិស្ថាន និងប្រជាជនទេ ប៉ុន្តែនឹងចូលរួមអភិវឌ្ឍជំនាញនិងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជន ដែលនឹងចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

| | |
|---|---|
| តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? | **គ្មាន** |

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនេះនឹងជួយលើកកម្ពស់សមភាពយេនឌ័រ លើភាពជាសហគ្រិនភាព ក្នុងវិស័យពាណិជ្ជកម្ម។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**ក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោង ប៉ុន្តែក៏ត្រូវមានការជួយសហការចូលរួមពីអ្នក ជំនាញជាតិ និងអន្តរជាតិ ដើម្បីជួយបំពេញបន្ថែមលើការងារបច្ចេកទេសផងដែរ។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**មិនទាន់មានការអនុវត្តបានពេញលេញនៅឡើយ ដោយសារមិនទាន់មានធនធានគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោង**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

3

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**ដៃគូអភិវឌ្ឍនានា ដែលមានជំនាញពាក់ព័ន្ធនឹងការជំរុញពាណិជ្ជកម្ម ឬ មានបំណងចូលរួមចំណែកជួយលើកម្ពស់ ផលិតផលក្នុងស្រុក និងអភិវឌ្ឍនវិស័យពាណិជ្ជកម្មនៅកម្ពុជា។**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 9,602.0 | 9,602.0 | 9,606.0 | 28,810.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 1,070.0 | 1,070.0 | 1,070.0 | 3,210.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 4,666.0 | 4,666.0 | 4,668.0 | 14,000.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 3,866.0 | 3,866.0 | 3,868.0 | 11,600.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 61,375.0 | 61,375.0 | 37,127.5 | 159,877.5 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 28,750.0 | 28,750.0 | 28,750.0 | 86,250.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 1,150.0 | 1,150.0 | 1,150.0 | 3,450.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 4,791.0 | 4,791.0 | 4,793.0 | 14,375.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 1,361.0 | 1,361.0 | 1,360.5 | 4,082.5 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 25,323.0 | 25,323.0 | 1,074.0 | 51,720.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 70,977.0 | 70,977.0 | 46,733.5 | 188,687.5 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 70,977.0 | 70,977.0 | 46,733.5 | 188,687.5 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: